**BMI0070**

# សម្ភាសន៍ជាមួយ ទុយ អោម ភេទប្រុស អាយុ៦៨ឆ្នាំ

មុខងារសម័យខ្មែរក្រហមៈ អនុលេខាស្រុកមានជ័យថ្មី (ស្វាយទាប)

ស្រុកកំណើតនៅភូមិដូនរមៀល ឃុំស្រែកោង ស្រុកបាភ្នំ ខេត្តព្រៃវែង

រស់នៅភូមិសង្កែ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១០

សម្ភាសដោយ សោម ប៊ុនថន

០១:៣៩:១០

២៣ទំព័រ

ប៊ុនថន : ខ្ញុំសួរអ៊ីដឹបូង ។ អ៊ីឈ្មោះអី?

អោម : ខ្ញុំត្រកូល ទុយ អោម ។

ប៊ុនថន : អ៊ីអាយុប៉ុន្មាន?

អោម : ឥឡូវនេះ៦៨ ។

ប៊ុនថន : អ៊ីនៅមាំ ដើរបាន ។ អ៊ីស្រុកកំណើតនៅណា?

អោម : នៅភូមិដូនរមៀល ឃុំស្រែកោង ស្រុកបាភ្នំ ខេត្តព្រៃវែង ។

ប៊ុនថន : កាលពីដើម តើអ៊ីមានបងប្អូនប៉ុន្មាននាក់?

អោម : បងប្អូន១០នាក់ ប៉ុន្តែស្លាប់អស់ហើយ នៅសល់តែ៥នាក់ ។

ប៊ុនថន : អ៊ីកូនទីប៉ុន្មាន?

អោម : កូនទី៥ ។

ប៊ុនថន : តើបងប្អូនស្លាប់ថ្មីៗ ក៏យូរហើយ?

អោម : ស្លាប់ចាស់ជរាផង និងស្លាប់សម័យនោះផង ។

ប៊ុនថន : ចុះឪពុកម្ដាយ?

អោម : ស្លាប់អស់ហើយ បើគិតមកដល់ឥឡូវអាយុជាង១០០ ។

ប៊ុនថន : កាលពីដើមចូលរៀននៅសាលាណាដែរ?

អោម : អ៊ីរៀននៅសាលាបឋមសិក្សាវត្តច្រកស្វាយ ។

ប៊ុនថន : អ៊ីរៀនដល់ថ្នាក់ទីប៉ុន្មាន?

អោម : បើគិតឆ្នាំ មិនបានគិតទេ ប៉ុន្តែរៀនបានថ្នាក់ទី៩ពីសង្គម ។

ប៊ុនថន ៖ កាលនោះគេរាប់ពីខ្ពស់មកទាបវិញ?

អោម ៖ ១២, ១១, ១០, ៩ ។

ប៊ុនថន ៖ បាន៤ឆ្នាំ ។ អ៊ំឈប់រៀននៅឆ្នាំណា?

អោម ៖ ឆ្នាំ១៩៥៧ ។ ឈប់រៀន អ៊ំចេញពីសាលាក៏មកបួស ។ បួសបាន៦ឆ្នាំ បើព្រះ៦វស្សា ។

ប៊ុនថន ៖ បួសនៅវត្តណា?

អោម ៖ វត្តប្រកស្វាយ ។ បួសហើយ អ៊ំចូលរៀននៅសាលាបាលីរងបានបីឆ្នាំ ក៏ប្រលងទៅធ្លាក់ ។ ធ្លាក់ពីសាលាបាលីរង ឈប់រៀនសាលាបាលី ក៏មករៀនខាងធម្មវិន័យបីឆ្នាំទៀត ។ ៣ឆ្នាំ ក៏ប្រលងជាប់បានសញ្ញាប័ត្រ ។

ប៊ុនថន ៖ គេហៅសញ្ញាប័ត្រអី?

អោម ៖ សញ្ញាប័ត្រធម្មត្រី ។ ខាងវិន័យ ខាងព្រះសង្ឃ ហៅសាលាបឋមសិក្សា និយាយខាងច្បាប់ព្រះ ។

ប៊ុនថន ៖ ចុះក្រោយពីបានសញ្ញាប័ត្រ?

អោម ៖ អ៊ំក៏ចាកសិក្ខាបទ ។ ឈប់ធ្វើលោក ។

ប៊ុនថន ៖ តើក្រោយមកអ៊ំធ្វើអី?

អោម ៖ ចប់ពីលោកមក អ៊ំមានគ្រួសារ ។ ឥឡូវអ៊ំសូមនិយាយខ្លីកុំឲ្យវែងពេក ។ ឆ្នាំ១៩៧០ សភាពការណ៍យើងរដ្ឋប្រហាររបស់ លន់ នល់ ទម្លាក់សម្តេចតា ក៏ដឹកនាំបាតុកម្មដឹកនាំរំលាយរដ្ឋអំណាចចាស់ មេឃុំ មេភូមិ សាលាស្រុក ក៏ចូលទៅរស់ ។ កាលនោះក៏ចូលទៅរួម កាលនោះវៀតណាមគេចូលមកដឹកនាំយើង ហើយខ្ញុំទៅរៀននៅជិតព្រំដែនក្រាំងលាវក្នុងស្រុកកំពង់ត្របែក ។ មានកងទ័ពវៀតណាមគេធ្វើមេដឹកនាំ ហើគេអត់និយាយអីទេ និយាយជាមួយអ៊ំថា អស់លោកទាំងអស់ តស៊ូដើម្បីរំដោះយកសម្តេចឳមកវិញ ។ ចូលធ្វើកងនៅនោះជាមួយវៀតណាម ។ ដឹកនាំ ហាត់រៀន ហ្វឹកហ្វឺនខាងបច្ចេកទេសបាញ់បោះវាថាឲ្យចប់ រៀនចេះហើយ វាយយកសម្តេចឳមកវិញ ។ ប៉ុន្តែកាលនោះលោក លន់ នល់ ។ ក៏នៅជាមួយចិនទៅ រៀនចប់បច្ចេកទេសបាញ់បោះអីណេះណោះហើយ ចូលមកវាយវិញ ជាមួយកងទ័ព លន់ នល់ ។

ប៊ុនថន ៖ វាយនៅកំពង់ត្របែក?

អោម ៖ កំពង់ត្របែក ។ កាត់ខ្សែភ្លើង កាត់ខ្សែលួស វាយនៅកអណ្តើក ។ វាយអស់ ខ្ញុំចូលដល់ ៧១ ។ ឆ្នាំ១៩៧១ គឺខាងខ្ញុំនេះ ឃុំស្រែកោង ស្រុកបាភ្នំនេះ ត្រូវរៀបចំមេឃុំ ភូមិ ។

ខ្ញុំក៏ប្រាប់មេវៀតណាម ខ្ញុំឈប់ធ្វើទាហានហើយ សុំមកធ្វើខាងឃុំវិញ ក៏គេឲ្យមក ។ ប្រគល់អាវុធឲ្យគេចប់ ខ្ញុំក៏មក ។ មកដល់គេរៀបចំមេឃុំហើយ មេឃុំស្រែកោង ហើយខ្ញុំគេឲ្យប្រធានសន្តិសុខ ។

ប៊ុនថន : សន្តិសុខឃុំ?

អោម : សន្តិសុខឃុំ ។ ចប់ពីនោះចេះតែដំណើរការ៧១, ៧២ រហូតដល់៧៩រំដោះ ។ ដល់រំដោះចប់ខ្ញុំគេលែងឲ្យនៅសន្តិឃុំហើយ គេយកទៅ មួយតំបន់២៨ លេខ២៨តំបន់២៨ ។

ប៊ុនថន : ភូមិភាគបូព៌ា?

អោម : បាទ ។ ដល់ចប់ ឲ្យដើរចេះ មិនដើរធ្វើអីទេ ដើរពិនិត្យតាមសហករណ៍ តាមភូមិ តាមឃុំ អត់ឃ្លានយ៉ាងម៉េច ខ្វះអី ខាតអី ។ ហ្នឹងមិនមែនជាប្រធានទេ ប៉ុនមាំតំបន់២៨ លើខ្ញុំតែម្តង ។ អើមើលសហករណ៍ណា អត់បាយ អត់ទឹក ខ្វះអី ខ្វះអី មន្ទីរពេទ្យសង្គមកិច្ចភូមិ ចូលមើលគ្រប់កន្លែងទាំងអស់ ។ ខទាហរណ៍ចូលមើលសហករណ៍នេះ ខ្ញុំចូលទៅមានស្អីទេ ទៅដល់មើលរោងបាយតែម្តង ។ តាមរោងបាយ ចុះម៉េចរាវម៉េះ? អើលោកប្រធានភូមិ អើសហករណ៍ គាត់ឲ្យខ្ញុំដាក់តែ១០កំប៉ុង ។ ចូលទៅកន្លែងពេទ្យ ពេទ្យតាមភូមិ ឈឺយ៉ាងម៉េច អីយ៉ាងម៉េច បងប្អូនឪពុកមាយ៉ាងម៉េច ថាមានតែថ្នាំសូន្យ បុរាណ ឥឡូវខ្វះថ្នាំអី ។ ខ្វះនេះ ខ្វះនោះតាមពេទ្យ អឹគ្រាន់សរសេរសំបុត្រ ឥឡូវទៅខាងសេដ្ឋកិច្ចតំបន់ ដឹកអង្ករ ៥បាវមក ថ្នាំនេះថ្នាំនោះចូលមកពេទ្យមក ។ ផុតពីនេះ ទៅនោះទៀត ។

ប៊ុនថន : កាលអឹនៅខាងសន្តិសុខដដែល?

អោម : ចប់ហើយអឹមកខាងតំបន់ ។

ប៊ុនថន : កាលនោះតំបន់២៨មានស្រុកអីខ្លះ?

អោម : ស្រុកពាមជរ ស្រុកត្របែក-កំពង់ត្របែក ស្រុកពាមរ ស្រុកមេសាង ស្រុកបាភ្នំ មាន៨ស្រុក ។ ទាំងស្រុកកំចាញមា ។ ឥឡូវមែនទែនចង់យល់អឹពីអីទៀត ។

ប៊ុនថន : ចង់យល់ពីប្រវត្តិរបស់អឹ?

អោម : ដល់ចប់ពីរឿងហ្នឹង ឆ្នាំ១៩៧៨ អឹឈប់ពីរឿងចឹងហើយ ឲ្យអឹទៅធ្វើអនុលេខាស្រុកមានជ័យថ្មី ក្នុងតំបន់២៣ ខេត្តស្វាយរៀង ។ ប៉ុនកាលនោះ មិនទាន់មកឈរនោះទេ អឹចុះទៅកំពង់រោទិ៍ ទៅប្រសូត្រ ទៅចន្ទ្រា ទៅសំរោង ទៅរមាសហែក ដោះស្រាយជីវភាពប្រជាជនដូចថា អត់ឃ្លាន ខ្វះខាតយ៉ាងម៉េច ជួយដោះស្រាយ ។ អើកាលនោះចូលភូមិភាគមានកិច្ចការអី រាយការណ៍ឡើងភូមិភាគ ។ ដល់និយាយពី៧៨ និយាយខ្ទីក៏បាន ។

ប៊ុនថន : និយាយវែងក៏បាន?

អោម : ដល់និយាយនៃពីរឿង កាលនោះអ៊ឹ សោ ភឹម គាត់មិនភូមិភាគ២០៣។ ពេលចប់មកគាត់ជាអនុប្រធានរដ្ឋជាមួយអ៊ឹ ខៀវ សំផន។ អ៊ឹ ខៀវ សំផន ជាប្រធានរដ្ឋ អ៊ឹ សោ ភឹម ជាអនុប្រធានរដ្ឋ តែគាត់ទទួលដាច់ដោយឡែកគឺ ភូមិភាគ២០៣ ហៅភូមិភាគបូព៌ា។ អ៊ឹទៅរៀនកាលនោះ លោកសម្តេច ជា ស៊ីម ប្រធានលេខ២១ ធ្លាប់ទៅរៀនជុំគ្នា។

ប៊ុនថន : តំបន់២១?

អោម : បាទ។ ហើយសម្តេច ហេង សំរិន កាលនោះគាត់ជាប្រធានកងពលលេខ៤ របស់ភូមិភាគបូព៌ា។ ប៉ុនដោយឡែកសម្តេចនាយកសព្វថ្ងៃនេះ ខ្ញុំចេះតែឆ្ងល់ កាលនោះគាត់នៅណាបានជាខ្ញុំមិនដែលជួបគ្នា។ បើលោកតា ជា ស៊ីម លោកតា ហេង សំរិន ធ្លាប់បានទៅរៀនក្នុងសាលាភាគនោះ។ ទទួលសភាពការណ៍ ៧៧, ៧៨, ៧៩ អាហ្នឹងខ្ញុំចង់និយាយមួយម៉ាត់ថា ខ្ញុំធ្វើអនុលេខាស្រុកមានជ័យថ្មី។ ខ្ញុំចេះតែគិត អញសម្រេចចិត្តយ៉ាងម៉េចចង់ចូលជាមួយ កាលនោះសភាពការណ៍មិនរៀបរយចូលវៀតណាម អើសភាពការណ៍ក្នុងវាចេះតែខ្លាំងហើយ អ៊ឹយើងខាងក្នុងនេះ។ ចេះតែគិត បើអញចូលទៅយួន យួនអញស្អប់យូរហើយ ចង់និយាយពីប្រវត្តិតែអុង ប្រវត្តិដើមវាយខ្មែរយើងចេះចុះ។ ហឺខាងនោះចូលហើយ យួនចូលសភាពការណ៍នោះ អញចូលទៅយួននឹកឃើញប្រវត្តិតែអុង។ អើ មិនចូលទេ តាំងចិត្តយួនសត្រូវសូរពូជ ដូនតាយើង ឥឡូវគិតម៉េចដាច់ចិត្តមិនចូល។ ដល់សភាពការណ៍ អើលោកក្លួយយល់ហើយ ថ្ងៃប៉ុន្មានអីហ្នឹង រថក្រោះវាចូលមក វៀតណាមវាចូលមក ខ្ញុំរត់គេច ទាំងអស់ក៏រត់មក មកនៅខាងខ្មែរក្រហម។ មកចូលធ្វើទ័ពទៀត វាយគ្នាចុះឡើង១ ក្រោយពីសន្និសីទក្រុងប៉ារីសហើយ មកខ្ញុំមកនៅនេះ។ ចូលធ្វើទាហានទៀត ធ្វើទ័ពទៀត អើខាងហ្នឹងមិនវាយខាងណោះ គេហៅរដ្ឋកម្ពុជា។ វាយចូលទៅក្នុង មុនមិនឆ្លងផ្លូវអំពិល អូរចក់អីហ្នឹង សរសេរសំបុត្រ បងប្អូនណាស្គាល់ខ្ញុំ ខ្ញុំដាក់ឈ្មោះ ទុយ អោម។ បងប្អូនណាស្គាល់ខ្ញុំឈ្មោះ ទុយ អោម ទោះបីជាទាហានក្តី ធ្វើអីក្តីបើឃើញសូមមកជួបគ្នា យើងមិនបាញ់គ្នា យើងជាតិខ្មែរនឹងខ្មែរអត់សម្លាប់គ្នាទេ សម្លាប់តែយួនទេ។ ដាក់អ៊ីចឹង ដាក់មីមួយឡាំងពីរឡាំង ទឹកដោះគោមួយឡាំងពីរឡាំង ចោលជាមួយសំបុត្រ តាមអាផ្លូវយើងមកពីបវេលមក ផ្លូវមកអំពិលប្រាំដើម។ ក៏មិនដែលឃើញជួបអីជាប់អី ដល់ចប់នោះតែនៅទៅ ទទួលអ៊ឹហ្នឹង គេឲ្យនៅឈរជើងនៅហៅ តំបូកក្នុងនៅត្រង់នេះ ខាងលិចភូមិរហាត់ទឹក ក៏ទាក់ទងជាមួយទាហានយើង ទាហានខ្មែរ។ ឥឡូវ

អាអូន អ្អែងកុំវាយគ្នាឲ្យសោះយើងខ្មែរ បើយួនមក ហើយមែនដែនការនេះដូចថាទាហាន យួនវាវាគគ្បាគចូលមក អាទាហានខ្មែរយើងថា ពូស្អែកយួនចេញមកវាយហើយ អើ អ្អែងមកមុនមក ពូបាញ់តែឡើងលើទេ អើដល់យួនមកមែនទែនតែម្តង ។ បានចប់សព្គ្រប់ ចរចារអីនេះហើយនេះ អឹសូមសរុប អើសមាហរណកម្មឆ្នាំប៉ុន្មានទេអឹភ្លេចហើយ ។

ប៊ុនថន : ៩៦?

អោម : អើ បានសម្តេចនាយកនេះថា យើងផ្សះផ្សាជាតិ បង្រួបបង្រួមជាតិ អំពាវមេកងពលឲ្យទៅជួប ។ ចប់សព្គ្រប់ បានថាឥឡូវគ្មាននរណាចាញ់នរណាឈ្នះទេ យើងចាប់ដៃគ្នាបង្រួបបង្រួមជាតិ តែកងទ័ពវាដកអស់ហើយ ។ បានសម្តេចប្រកាសចាប់ដៃគ្នា ផ្សះផ្សាគ្នា ជាតិយើងតែមួយ ប៉ុនទៅខ្មែរក្រហមមួយចំនួនតូចទៀត នៅអន្លង់វែងអីហ្នឹង ។ បានសម្តេចនាយកប្រកាសផ្សះផ្សា ខ្ញុំរូបរួមសាទរជាមួយសម្តេចនាយក មកចុះនៅសាលារៀនម៉ាឡៃ ។ អីចឹងខ្ញុំសូមសរុបមកវិញថា មានតែសម្តេចនាយក ហ៊ីខស្បាហ៍ទុកកិត្តិយសគាត់តាំងពីទៅប្រជុំនៅអឺរ៉ុបបានកិត្តិយសសន្តិភាព ។ បានហើយ ឥឡូវខ្ញុំមានតែសម្តេចនាយក មានតែរាជរដ្ឋាភិបាលយើងហ្នឹងឯង ដែលជួយឲ្យប្រទេសជាតិ ឲ្យម៉ាឡៃយើងមានប៉ុណ្ណឹង មើលឥឡូវថ្ងៃទីប៉ុន្មានមកចាក់កៅស៊ូ ។

ប៊ុនថន : អញ្ចឹងខ្ញុំសូមសួរអីពីប្រវត្តិនៅម៉ាឡៃ ។ តើមកដល់ដំបូងគេហៅម៉ាឡៃ?

អោម : នៅម៉ាឡៃហ្នឹង ហួសភ្នំនេះ ភ្នំខាងកើតនេះឈ្មោះភ្នំម៉ាឡៃ ដល់ស្រុកហ្នឹងឈ្មោះស្រុកម៉ាឡៃ ប៉ុនភ្នំមានច្រើនណាស់ ភ្នំវែង ភ្នំអីច្រើនណាស់ ។ ហ៊ីភ្នំរូងនេះ ចាំអឹនិយាយ ប្រវត្តិនេះនៅលើអឹទាំងអស់ ព្រំដែននេះ មកទល់នេះ ។ ភ្នំរូងនេះពីដើមមក មើលដែនទីក៏អត់មានដែរ ប៉ុនទំនៀមទម្លាប់ហៅ បឹងត្រកួន ។ ប៉ុនឥឡូវចាំអឹនិយាយពីប្រវត្តិភ្នំរូងបន្តិច ដោយសភាពការណ៍សង្រ្គាម វៀតណាមដែលចូលមកនោះមិនដឹងជាជីកអី អឹរកទឹកមិនឃើញដែរ បើជីកដៃមិនបានទេ ភ្នំរូងនេះ ។ ដូចថា ភ្នំវាចេះ ជីកទៅចឹង ប្រវែងប្រហែលម្តៃម៉ែត្រ កាច់មកនេះ ហីកាច់នោះមិនកាច់ធម្មតាទេ ហើយចាក់ស៊ីម៉ង់ត៍មួយគ្រែៗ ។ គឺថាជីកទៅចឹង ម្ភៃម៉ែត្រចាក់ស៊ីម៉ងត៍ទៀត ទុកមួយគ្រែៗទៅ ដល់ត្រង់ហ្នឹងចាក់ជណ្តើរឡើង ជណ្តើរដែកឡើងមានគម្របស៊ីម៉ង់ ។ គេចកាច់មកហ្នឹងទៀត ម្ភៃម៉ែត្រចាក់ឡើងទៀត ហើយមួយគ្រែៗចាក់ស៊ីម៉ង់ត៍ ហើយមិនជីកវាក់ទេ ជីកដល់បាតភ្នំតែម្តង ។ ចឹងបានអឹថា បើជីកដៃមិនកើតទេ កាលនោះអឹនៅខ្មែរក្រហម ស៊ុំដីថៃដាក់ ដាក់៧៥ ដែវាឲ្យដាក់ ។

ប៊ុនថន : គេហៅអី?

អោម ៖ កាំភ្លើង៧៥យើង។ វាយប្រហែល បើគិតជាគ្រាប់ប្រហែលជា៣លាន វាយមិនបែកទេ ភ្នំរូងនោះ។

ប៊ុនថន ៖ ជីកចូលនោះ?

អោម ៖ បាទ វាយម៉េចបែកបើរូងភ្នំហើយ។ អាគម្របឡើងម៉ាជណ្តើរកាច់មួយ ជណ្តើរឡើងបិទគម្រប។ ថៃវាឲ្យវាយ ដាក់៧៥យើង បើគ្រាប់ប្រហែលជាពីរឡាន។

ប៊ុនថន ៖ នៅក្នុងរូងភ្នំ?

អោម ៖ រូងភ្នំ ហើយមិនមែនរាក់ទេ មិនមែនជីកនឹងដៃទេ បានឈ្មោះឥឡូវហៅភ្នំរូង។ ហីក្រោយពីយើងសន្តិភាពស្រួលបួលហើយ អាមេរិក បារាំង ចិន ជប៉ុន មកសុំទស្សកិច្ច មកចំចូលទៅមើលរូង។ ចុចពិលមិនឆេះទេ កាន់ទានប៉ុនៗកដៃនេះ នាំគ្នាចូល។ មើលឆ្នាំប៉ុន្មានទេ អឹរកនឹកមួយភ្លែតសិន ឆ្នាំ១៩៩៨ កម្លាំងសន្តិសុខយើងនាំភ្ញៀវចូល ឃើញពស់មួយគូរប៉ុណ្ណោះនៅក្នុងនោះ គ្រាន់តែឃើញពស់លែងហ៊ានចូល។ លែងហ៊ាននាំភ្ញៀវចូលទាំងអស់ ព្រោះពស់មកនៅក្នុងរូងហើយ មិនដឹងធ្វើម៉េច យកម៉ីនគោនដាក់កម្ទេចចោលរូងហ្នឹង ប៉ុនវាមិនខ្ទេចទាំងអស់ទេ។ ឥឡូវវាដុះព្រៃអស់ហើយ អត់មាននរណាហ៊ានចូលទៀតទេ បានជាប់ឈ្មោះភ្នំរូង។

ប៊ុនថន ៖ ខាងយួនជីក?

អោម ៖ ខាងនោះ ហើយមិនជីកដៃទេ ខ្ញុំប៉ាន់ ចុះពីលើកំពូលភ្នំមកដល់បាតភ្នំ។ ដឹងប្រើម៉ាស៊ីន ឬប្រើអីអឹឆ្លល់ទល់ឥឡូវហ្នឹង ហើយចាក់ស៊ីម៉ង់ត៍។

ប៊ុនថន ៖ សព្វថ្ងៃមានពីណាចូលទេ?

អោម ៖ អត់ចូលទេ ម្យ៉ាងវាដុះព្រៃផង ដុះអីផង អត់ហ៊ានចូលទេ ប៉ុននៅជារូងធម្មតា។ អីចេះអឹសួររឿងប្រវត្តិអឹ បើនិយាយវាវែងឆ្ងាយណាស់ ទៅស្រុកថៃទៅអីនោះ។ និយាយសរុបមកវិញ ដល់៩៦ សមាហរណកម្មហ្នឹង រូបរួម ចុះចូលផ្សះផ្សា បានសម្តេចនាយកចូលមក មានតែរឿងយើងផ្សះផ្សាប្រទេសជាតិយើង ហើយបានរហូតមានផ្លូវ មានសាលា វាមានមន្ទីរពេទ្យដោយសារសម្តេចនាយក។

ប៊ុនថន ៖ ចង់សួរអឹទៀត។ ចុះម៉ាឡៃ?

អោម ៖ ម៉ាឡៃ យកតាមឈ្មោះភ្នំ មកដាក់ស្រុក។

ប៊ុនថន ៖ ចុះអឹមកដល់ដំបូងគេហៅម៉ាឡៃ ឬមិនទាន់ទេ?

អោម ៖ គេហៅហើយ ព្រោះភ្នំនោះ ភ្នំម៉ាឡៃ ។ ដល់ផ្សះផ្សារជាតិ បង្រួបបង្រួមជាតិចប់ ហ្នឹងក៏យកម៉ាឡៃនោះ ជាស្រុកម៉ាឡៃ ។

ប៊ុនថន ៖ ឆ្នាំប៉ុន្មាន?

អោម ៖ មើលពីគិតតាំងពីមុនផ្សះផ្សា យកភ្នំម៉ាឡៃជាស្រុកម៉ាឡៃ ។

ប៊ុនថន ៖ ពីមុនមកអ៊ីមានដឹងថា ម៉ាឡៃ ស្ថិតនៅក្នុងតំបន់ណា ស្រុកអីទេ?

អោម ៖ អត់ទាន់មានចែកជាតំបន់នេះ តំបន់នោះទេ ប៉ុន្តែគ្រាន់តែកំណត់ចេះ តាំងពីចៅកែយ៉ គាត់ទិញឈើពីសង្គមដាក់ឈ្មោះផ្លូវ១០២ ។ អាផ្លូវដែលបែកចេញពីកូនដីរមក ឈ្មោះផ្លូវ ១០២ អាហ្នឹងចូលក្នុងដែនទី ហើយភ្នំម៉ាឡៃមាន អាភ្នំវែងមិនមានឈ្មោះទេដោយខ្សែភ្នំជួរភ្នំវាវែងរហូតទៅហ្នឹងទៅហៅភ្នំវែង ។

ប៊ុនថន ៖ តើអ៊ីដឹងថានៅក្នុងតំបន់ ភូមិភាគអី?

អោម ៖ មិនទាន់មានលេខដូចថាតំបន់ ឬលេខ ខេត្តអីទេ ។ ប៉ុន្តែមែនទែន បើសរុបពីប្រវត្តិដើមវានៅក្នុងទឹកដីខេត្តបាត់ដំបង ។

ប៊ុនថន ៖ ភូមិភាគពាយ័ព្យ?

អោម ៖ បើនិយាយភូមិភាគពាយ័ព្យ ។

ប៊ុនថន ៖ ដឹងតំបន់ច្បាស់លាស់ទេ?

អោម ៖ អត់ដឹងលេខទេ ហើយស្រុកនេះពីមុន ភូមិនេះពីមុនហៅភូមិដូងដោយស្រុកថៃមានដើមដូងច្រើនជាប់ព្រំដែនយើងសព្វថ្ងៃនេះ ។ អញ្ចឹងហៅថាភូមិដូង ដល់សភាពការណ៍យើងរៀបចំស្រុកទៅ យកភ្នំម៉ាឡៃស្រុកម៉ាឡៃចូលខេត្តបន្ទាយមានជ័យ ។

ប៊ុនថន ៖ ចុះឃុំ?

អោម ៖ អើពីមុនបឹងបេងវាចេះ ទើបនឹងព្រឹឈ្មោះពេលចូលមកនៅ ព្រោះកន្លែងនោះសុទ្ធតែដើមបេង ដើងភ្នំ សុទ្ធតែដើមបេងច្រើនណាស់ ។ មិនដឹងហៅអី មានតែភូមិបឹងបេង ។ ដល់រៀបចំស្រុកម៉ាឡៃហើយ បានបង្កើតភូមិ ភូមិសង្កែសុទ្ធតែដើមសង្កែ ។ ទៅទៀត វាលែងបឹងហើយ ភូមិភ្នំរូង វត្តភ្នំរូង ។ តទៅទៀត មានដើមចំបក់មួយ ភូមិចំបក់ ដល់នោះមានសុទ្ធតែដើមល្ហុងក្នុងព្រៃ ដាក់ភូមិល្ហុ ។ ឥឡូវឃុំបឹងបេងមានតែ៥ភូមិ មានភូមិសង្កែ ភ្នំរូង ទៅទៀតភូមិចំបក់ ទៅទៀតភូមិល្ហុ ភូមិជ្រៃ ។

ប៊ុនថន ៖ ដាក់ឈ្មោះតាមដើមឈើ?

អោម : បាទ ប៉ុនមិនមានចូលក្នុងដែនទីទេ ទើបតែបង្កើតថ្មី ក្រោយយើងរួបរួមផ្សះផ្សាជាតិ ដាក់អញ្ចឹង ។

ប៊ុនថន : ជាប់រហូតមកដល់ឥឡូវ?

អោម : បាទរហូតមក ។ ភូមិសង្កែ ភូមិភ្នំរូង ភូមិចំបក់ ភូមិជ្រៃ ភូមិល្វា ។

ប៊ុនថន : នៅទីនេះព្រៃដល់ណាដែរ?

អោម : ព្រៃចាប់ពីខាងកើតថ្នល់នេះ សុទ្ធតែព្រៃ អានេះមានតែស្បូវ វាលស្បូវ អើស្រុកយើងហៅថ្លាំង មានដើរឈើមួយដើមៗ ។ ប៉ុនចាប់ពីនេះទៅ ពីមុនអឺដើរបាញ់មានព្រៃ ចាប់ពីខាងកើតថ្នល់ សុទ្ធតែមាន់ព្រៃ ឆ្កុះយប់ក្តាន់ញែង សំពោច ឈ្លូស ជ្រូកព្រៃ ពេញភ្នំរូង ។ ចុះសុទ្ធតែព្រៃភ្នំនោះ ។

ប៊ុនថន : ចុះនៅផ្សារម៉ាឡៃជាព្រៃដែរ?

អោម : មិនមែនជាព្រៃទេ មានតែផ្ទះ កុម្ពុប្ញស្សី ផ្សារម៉ាឡៃ អត់មានឈើព្រៃធំដុំទេ ។ ហ្នឹងមែនទែនអឹដឹងច្បាស់ណាស់ ទាំងផ្សារព្រំដែន ទាំងផ្សារម៉ាឡៃ ទាំងភូមិយើងសព្វថ្ងៃក៏ដោយព្រោះចូលមកឆ្នាំ៩០ ។ ឆ្នាំ៩០ បានដឹកចេញពីថៃមកនៅហ្នឹង ហីកាលនោះមានកងពិសេសគេ រាវតែម៊ីនចូលតាមផ្លូវហៅច្រកស-១៥ ឥឡូវគេហៅភូមិត្រសេកជ្រំ ។ រាវមីនដឹកចូលមក ឡានដឹកមក ចែកគ្នានៅ រស់នៅហ្នឹង ។

ប៊ុនថន : អឹដំបូងនៅខាងស-១៥?

អោម : នៅសាលារៀនវាលហាត់ ។

ប៊ុនថន : នៅម៉ាឡៃនេះមានដីរទេ?

អោម : ដីរមិនមានទេ ទៅខាងមុខ ខាងភ្នំវែង ទៅខាងភ្នំគ្រាប់បានមានដីរ ។ នៅនេះមានត្រឹមឈ្លូស ជ្រូកព្រៃ មាន់ព្រៃ ហើយនឹងក្តាន់ញែង យប់ដើរឆ្កុះតាមហ្នឹង ។

ប៊ុនថន : មានប្រជាជនរស់នៅ?

អោម : អត់ទាន់មានទេ នៅតាមមាត់អូរព្រំដែនទាំងអស់ សុទ្ធតែកងទ័ពទាំងអស់ ។

ប៊ុនថន : មានប្រជាជនមករស់នៅលាយឡំទេ?

អោម : ប្រជាជន ចង់និយាយថា ប្តី កងទ័ព ប្រពន្ធ ប្រជាជន មិនមែនជាប្រជាជនរកស៊ីទេ ។ ប្តីទាហាន ប្រពន្ធនៅហ្នឹង ។

ប៊ុនថន : ចុះពេល៧៩អឹមកដល់ភ្លាម?

អោម : នោះដឹកទៅតាមព្រំដែន តាមកាកបាទ ទៅជិតស្រះកែវ ជិណាៗអត់មាននៅទេ ។

ប៊ុនថន :   អ៊ឹមកដល់ដំបូងជាកងទ័ព?

អោម :   បាទ ៗ

ប៊ុនថន :   អ៊ឹមកដល់នេះទេ(ម៉ាឡៃ) ?

អោម :   ដល់ ប៉ុនសភាពការណ៍ខ្លាំងរត់ចេញទៅអស់ ទៅជំរំស្រុកថៃ ៗ

ប៊ុនថន :   កាលនោះអ៊ំនៅកងប៉ុន្មាន?

អោម :   ៤៥០ កងពល៤៥០ ៗ

ប៊ុនថន :   នៅជាមួយ…?

អោម :   សុខ ភាព មេកងពល មេ សួស ហុង ៗ

ប៊ុនថន :   សួស ហុង ឥឡូវគាត់នៅរស់?

អោម :   នៅ ឥឡូវឡើងឧត្តមសេនីយ៍អស់ហើយ ៗ

ប៊ុនថន :   នៅនេះអ៊ំមានប៉ះគ្នាជាមួយកម្លាំងរដ្ឋកម្ពុជាទេ?

អោម :   ប៉ះដូចអ៊ំនិយាយពីដើមម៉ិញ ៗ ប៉ះអញ្ចេះ អត់វាយទេ ទាក់ទងអ៊ំជាភ្នាក់ងារមួយដូចថា រដ្ឋកម្ពុជា ទាហានគេនៅឯណោះ អ៊ំនៅណេះ ៗ ចូលទាក់ទងតាមរយៈអ្នកស្រុកអ្នកភូមិចូលមកជួប សួរថាមេទាហានឈ្មោះអី ទាក់ទងតាមរយៈបងប្អូនចេញចូលមករកស៊ី ៗ ឲ្យមកជួប ខ្ញុំស្អែកប៉ុណ្ណោះ ដល់អ៊ីចឹងមេទាហាននោះមកជួបគ្នា ៗ ឥឡូវបេះអាអូន អើគេប្អូនខ្ញុំថា អាអូនខ្មែរ បង អ៊ំក៏ខ្មែរ យើងកុំបាញ់គ្នា រាប់អានគ្នាចុះឡើងរកលុយឲ្យទៀត ផ្តល់លុយឲ្យទៀត ៗ អើកាលនោះលុយយើងរៀបរយ អ្ហែងយកលុយមួយពាន់ពីរពាន់ទៅ ៗ

ប៊ុនថន :   មួយពាន់ពីរពាន់បាត?

អោម :   ហ្នឹងហើយ ៗ ថាអ្ហែងកុំបាញ់យើង គ្នាយើងកុំបាញ់ ហើយមកជុំនឹងអ៊ំរាល់ព្រឹក ៗ ជូនកាលយកមាន់មក ស្រាមួយកាដុងមកជុំហូបជាមួយគ្នា ៗ ប៉ុន្តែអ៊ីចេះ ពេលណាឡើងវាយត្រូវរាគត្បាត បងស្អែកវាយ អើអ្ហែងមកមុន ថាអើពួកខ្ញុំខ្មែរគេឲ្យឡើងមកមុន បាញ់ប្រោកប្រាក យួនមកក្រោយដាក់តែម្តង ៗ វាខុសគ្នាមែន ខាងណេះខ្មែរក្រហម ខាងនោះរដ្ឋកម្ពុជា ប៉ុនយើងជុំគ្នាខ្មែរនិងខ្មែរយើង ហីកាលនោះមកផឹកជុំគ្នា ៗ

ប៊ុនថន :   កាលនោះអ៊ំនៅកងប៉ុន្មាន?

អោម :   កង៤៥០ ប៉ុនវរសេនាធំ១០៧ ៗ ឈរជើងនៅដំបូកក្នុង ឥឡូវម៉ាសឿ ល្មា ម៉ាចំណោមរូបគោនោះ… ៗ

ប៊ុនថន :   អ៊ំប្រធានខាងចរចារ?

អោម ៈ ហ្នឹងហើយ អ៊ឹមិនមែនប្រធានខាងទាហានទេ ប្រធានខាងទំនាក់ទំនងពាក្យថាចរចារ ។

ប៊ុនថន ៈ គេហៅអីវិញ?

អោម ៈ គេហៅផ្នែកទំនាក់ទំនង ប៉ុនលើវរសេធំទៀត ម៉ាផ្នែកប្រជាជន ។ អ៊ឹចង់ទាក់ទងម៉េច កាលនោះមិនទាក់ទងត្រឹមប្រជាជនទេ ទាំងចៅហ្វាយស្រុកនៅមង្គលបូរី សុទ្ធលេខជាប់គ្នាទាំងអស់ ។ ប៉ុនកាលនោះមិនទាន់មានទូរស័ព្ទទេ ប្រើគេអូរ ។ បងឯងនៅនោះ ខ្ញុំនៅឯណោះ ប៉ុនប្រជាជនចេញចូលធម្មតាព្រៃ កាប់ឈើ កាប់ឫស្សី ចេញចូល ។ ប៉ុនដោយឡែកវាយស្អែក អានោះឲ្យដំណឹងមកក្លាម គេអូរជួបគ្នា អើអ្នែងមកមុនមក អញវាយអ្នែងមុន ។ បាញ់ប្រោកប្រាកទៅ គ្រាប់ខ្ទះអី ម៉ាទូសៀ ពីរទូសៀ ប៉ុនអាក្រោយមកសុទ្ធតែដាក់ ។

ប៊ុនថន ៈ គ្រាប់បានមកពីណាអ៊ឹកាលនោះ?

អោម ៈ ឃ្លាំងធំណាស់ ។ កាលនោះគេហៅ ៥-១០០ នៅដីថៃ ស្រុកថៃ ។ ត្រូវការពីរឡានដឹកវីបៗ ។

ប៊ុនថន ៈ មកពីណា?

អោម ៈ អ៊ឹមិនយល់ថា ពីចិន ពីខាងណាៗទេ ។ ប៉ុននិយាយឃ្លាំងធំនៅ ៥-១០០ ជាប់មាត់សមុទ្រនោះឯង ។

ប៊ុនថន ៈ អ៊ឹកាលនោះខាងទំនាក់ទំនង?

អោម ៈ ទំនាក់ទំនង ។

ប៊ុនថន ៈ អ៊ឹនៅខាងលើ?

អោម ៈ បាទនៅខាងកងពល៤៥០ម៉ាមុខសញ្ញាហ្នឹង ។

ប៊ុនថន ៈ អ៊ឹមានទាក់ទងទៅគ្រប់កន្លែងទេ?

អោម ៈ ទេ អ៊ឹទទួលម៉ាមុខសញ្ញា១០៧, ១០៨ផ្សេង, ១០៩ផ្សេង ។

ប៊ុនថន ៈ មានវាយគ្នាធំទេ ពេលអ៊ឹរត់ទៅថៃ?

អោម ៈ ដូចជាមិនធំប៉ុន្មានទេ គ្រាន់តែកាំភ្លើងធំទិញមក ប្រជាជនលែងហ៊ាននៅ ក៏នាំគ្នាចេញទៅរត់ចូលដីថៃ ។

ប៊ុនថន ៈ ឆ្នាំប៉ុន្មាន?

អោម ៈ ៨៣, ៨៤, ៨៥ ។ ៨៥, ៨៦ហ្នឹង ។

ប៊ុនថន ៈ ប្រជាជនរត់ចូលថៃ?

អោម ៈ រត់ទៅជំរុំ កាកបាទគេចិញ្ចឹម ជួយឲ្យអង្ករ ។

ប៊ុនថន ៖ អ៊ំនៅដដែល?

អោម ៖ ហ្នឹងហើយ ។

ប៊ុនថន ៖ គ្រួសារអ៊ំមកជាមួយអ៊ំទេ?

អោម ៖ អត់ទេ ឲ្យទៅនៅដីថៃទាំងអស់ តែអ៊ំចូលមកខាងក្នុងនេះ ។

ប៊ុនថន ៖ អ៊ំចង់សួរទៅក្រោយបន្តិច ពីប្រវត្តិអ៊ំកាលនៅស្រុក ។ កាលរំដោះភ្នំពេញហើយអ៊ំនៅកំពង់ត្របែក?

អោម ៖ ស្រុកបាភ្នំ មិនមែនកំពង់ត្របែកទេ ។

ប៊ុនថន ៖ អ៊ំនៅនោះដល់ឆ្នាំប៉ុន្មាន ហើយម៉េចបានជាគេផ្លាស់ទៅស្វាយរៀង?

អោម ៖ អានេះចូលមក៧៥-៧៥ទេ ពួកលោក លន់ នល់ ចាញ់អស់ហើយ មិនខ្មែរក្រហមចូលមកគ្រប់គ្រប់ឆ្នាំ១៩៧៤ ។ រំដោះ មិនខាង លន់ នល់ ចាញ់ លើខ្មែរក្រហមគ្រប់គ្រង់ ។

ប៊ុនថន ៖ អ៊ំនៅបាភ្នំ?

អោម ៖ ស្រុកបាភ្នំ ។

ប៊ុនថន ៖ កាលនោះអ៊ំនៅខាងសន្តិសុខស្រុក?

អោម ៖ ទេ អ៊ំកាលនោះបើនិយាយទៅ នៅខាងក្រសួងកសិកម្ម ។ ដើរតែផ្សព្វផ្សាយពីរឿងស្ទូងដក ធ្វើស្រែធ្វើចំការ ។

ប៊ុនថន ៖ ពេលអ៊ំផ្លាស់ទៅមានជ័យថ្មី ខាងណាផ្លាស់?

អោម ៖ នោះ៧៦ហើយ ។ ខាងគណតំបន់២៤ ដែលអ៊ំនិយាយម៉ិញនេះ ឲ្យអ៊ំចុះទៅរៀបរយ ។ មិនមែនចុះរៀបរយទេ ឲ្យអ៊ំចុះទៅពិនិត្យតែម្តង ពិនិត្យសភាពការណ៍ តើសហករណ៍ប្រជាជនហូបចុកគ្រប់គ្រាន់ មិនគ្រប់គ្រាន់ ឈឺ ចាញ់ ម៉េចៗ ។ អ៊ីចឹងបានអ៊ំដើរសព្កន្លែង ដើរទៅមើលនេះ ទៅមើលនោះ សហករណ៍នោះបបរម៉េច អីម៉េច ហូបគ្រប់មិនគ្រប់ ឈឺចាប់ម៉េចខ្វះសម្លៀកបំពាក់ម៉េចៗ?

ប៊ុនថន ៖ អ៊ំផ្តល់ឲ្យ?

អោម ៖ បាទ អ៊ំមិនបាច់មកទេ ។ សរសេរសំបុត្របន្តិចថា ខ្វះសម្លៀកបំពាក់ កងចល័តអីម៉េចគេផ្តល់ឲ្យតាមហ្នឹង ។

ប៊ុនថន ៖ គណតំបន់គាត់នៅព្រៃវែងដែរ?

អោម ៖ ទេ គាត់ផ្លាស់មកពីភូមិភាគមក ម៉ាជំនាន់នៅជាមួយអ៊ំ សោ ភឹម ឈ្មោះ អ៊ំចាន់ ។

ប៊ុនថន ៖ ចាន់អី?

អោម ៖ ត្រកូលគាត់ឈ្មោះ សេង ហុង មកនេះឈ្មោះអ៊ឹ ចាន់ ។

ប៊ុនថន ៖ មិនមែន ចាន់ ចក្រី?

អោម ៖ មិនមែនទេ នោះផ្សេងទៀត ។ បើរឿង ចាន់ ចក្រី អ៊ឹដឹងរឿងច្រើនណាស់ ប៉ុន្តែមិនបាច់និយាយទេ ។

ប៊ុនថន ៖ មិនអីទេ ។ កាលនោះគាត់នៅខាងបូព៌ដែរ?

អោម ៖ រឿងអ៊ឹ អ៊ីចឹងបានអ៊ឹដេកគិត អញគួរតែសុំសម្តេចនាយកនៅភ្នំពេញដែរ រឿងនិយាយលេង ។ ដល់ទឹកពិបាកពេក រកនេះមិនបានរកនោះមិនបាន មិនស្រួលអញទៅសុំសម្តេចនៅភ្នំពេញ សម្តេចគេដោ ។ ប៉ុនច្បាស់ជាគាត់មិនស្គាល់ទេ បើអ៊ឹ ហេង សំរិន អើអ៊ឹ នួន ជា អើនៃ... ។

ប៊ុនថន ៖ ជា ស៊ីម?

អោម ៖ បាទ ជា ស៊ីម ធ្លាប់ទៅរៀនជាមួយគ្នា ។ អើកាលនោះដឹង គាត់លេខាតំបន់២១ សម័យនោះ អ៊ឹ នួន ជា អើនៃ... ។ បើលោកតា ហេង សំរិន ប្រធានកងពលលេខ៤របស់ភូមិភាគបូព៌ ភូមិភាគ២០៣ ។

ប៊ុនថន ៖ ខស្សាហ៍ឡើងទៅប្រជុំជួបគ្នា?

អោម ៖ ប្រជុំជួប តែប្រហែលយូរហើយ តាមមើលភ្លេចហើយក៏មិនដឹង ។

ប៊ុនថន ៖ បើរៀបរាប់គាត់ចាំទេ?

អោម ៖ ទេបើរាប់រៀបកាលនោះ អាចគាត់នៅចាំ ។ ឥឡូវមិនបាច់ទេ អ៊ឹនៅនេះមានស្រែ មានចំការហើយ មានផ្ទះប៉ុណ្ណឹងហើយ ហើយជាគ្រឹះព្រំដែនផង ។ អ៊ីចឹងបានជារឿងទំនាស់ជាមួយសៀមនេះ ចេះតែប្រាប់ក្មួយ ចៅ ប្អូននេះ បើវាយអែ្ហងវាយ ។ អ៊ឹចាស់ហើយ ពូចាស់ហើយ លួនយកគ្រាប់ឲ្យអែ្ហងទៀត ។ អែ្ហងវាយមុខឲ្យខំ អ៊ឹវាយលែងកើតហើយ ភ្នែកងងឹតហើយ ប៉ុនលួនយកគ្រាប់ យកបាយឲ្យឯងទៀត ខំ ។ ចេះនិយាយលេងជាមួយក្មួយៗកងទ័ព ។

ប៊ុនថន ៖ ខស្សាហ៍ឡើងទៅប្រជុំនៅភ្នំពេញ ឬមន្ទីរភូមិភាគ?

អោម ៖ ទេ និយាយតែសម័យនោះទេ ។

ប៊ុនថន ៖ បាទ នៅភ្នមពេញ ឬមន្ទីរភូមិភាគ?

អោម ៖ ទេនៅមន្ទីរភូមិភាគ នៅស្វាង ។ ឥឡូវស្រុកស្វាង ។

ប៊ុនថន ៈ ខេត្តកំពង់ចាម?

អោម ៈ កាលនោះមន្ទីរភូមិភាគ ។ ទៅប្រជុំនៅសាលាស្រុកសួង ។ បាន៧៨-៧៩ បានចប់គ្នា កាលជំនាន់ សុន សេន ហៅ តាខៀវ ។

ប៊ុនថន ៈ ចុះអ៊ីផ្លាស់ទៅមានជ័យថ្មី?

អោម ៈ កាលនោះ៧៦, ៧៧ហើយ សភាពការណ៍កាន់តែដុនដាប ។

ប៊ុនថន ៈ អ៊ីសុំទៅ ក៏ខាងលើ?

អោម ៈ ខាងលើចាត់ចែង ចាត់តាំងនោះ ។ មិនមែនអ៊ីចេះតែដើរ ។

ប៊ុនថន ៈ កាលនោះស្រុកមានជ័យថ្មី មានស្រុកអីខ្លះ?

អោម ៈ និយាយពីតំបន់២៣ ខេត្តស្វាយរៀង ឥឡូវគេហៅស្រុករំដួល ស្វាយទាប កំពង់រោទិ៍ ប្រសូត្រ ចន្ទ្រា រមាសហែក សំរោង ក្រសាំង ។ ប៉ុនឥឡូវមានជ័យថ្មី ហៅស្រុកស្វាយទាប ។ រមាសបែក ចន្ទ្រា ប្រសូត្រ ។

ប៊ុនថន ៈ ទាំងអស់ចូល២៣?

អោម ៈ កាលនោះហៅតំបន់២៣ ខេត្តស្វាយរៀង ឥឡូវយើងខេត្តស្វាយរៀងដដែល ។

ប៊ុនថន ៈ កាលនោះអ៊ីអនុលេខា ចុះលេខាស្រុកឈ្មោះអី?

អោម ៈ ឈ្មោះ ហុង ប៉ុន្តែឈ្មោះអីទេ ។ ប៉ុនស្លាប់អស់ហើយ ។

ប៊ុនថន ៈ គាត់អ្នកស្រុកនោះដែរ?

អោម ៈ អត់ទេ មកពីស្ទឹងត្រែង ប៉ុនស្លាប់ម៉ាជំនាន់រត់លូន ។

ប៊ុនថន ៈ ចុះពេលអ៊ីផ្លាស់ទៅ សោ ភឹម បាត់ឬនៅ?

អោម ៈ នៅ ដេញបែកគ្នាត្រឹមសម័យ៧៩ សភាពការណ៍កងទ័ពវៀតណាមចូលម៉ាសម័យនោះ ។

ប៊ុនថន ៈ ចុះ សោ ភឹម គាត់ខ្លួន?

អោម ៈ សោ ភឹម គាត់ប្រធានភូមិភាគបូព៌ា គេហៅភូមិ២០៣ ហើយម៉ាជំនាន់ខ្មែរគ្រប់គ្រងនោះ គាត់ជាអនុប្រធានរដ្ឋ អ៊ឹ ខៀវ សំផន ជាប្រធានរដ្ឋ ប្រធាននិងអនុប្រធាន ។ ប៉ុនយួនថាបាញ់ស្លាប់ សភាពការណ៍ជិតបះបោរ សភាពការជិតច្របូលច្របល់ ។ គាត់រត់មិនរួចទេ គាត់មិនទៅជាមួយអ៊ីនោះណា គាត់រត់អត់រួច តាមមើលយើងថា បាញ់ស្លាប់ ឬគេចាប់បានមុននៅកំពង់ចាម ខាងកើតមេគង្គ ។ អាចស្លាប់ហ្នឹងឯង មិនរត់ចេញទេ ។

ប៊ុនថន ៈ ប៉ុនអ៊ីអត់ដឹងទេ?

អោម ៖ អត់ដឹងទេ ប៉ុនដឹងថាស្លាប់ៗ សភាពការណ៍នោះ យន្តហោះព្រាតព្រោង ទាល់តែជិតចប់ ៧៩ៗ ចប់រឿងនោះ បាន ៧ មករា យើងហ្នឹង បន្តបន្ទាប់មក ចូលឆុលមក រួមគ្នាមក រត់ក្រោះចូលមកភ្នំពេញៗ

ប៊ុនថន ៖ បាត់ សោ ភីម អីនៅដដែល ឬផ្លាស់ទៅណា?

អោម ៖ នៅៗ

ប៊ុនថន ៖ ចោះខាងណាមកជំនួស សោ ភីម?

អោម ៖ មាន តាចាន់ ឈ្មោះ តាចាន់ ជាតំណាងភូមិភាគចុះមកដឹកនាំពីរបីតំបន់ៗ តំបន់២៤, ២៣, ២៥ លើតាចាន់ៗ

ប៊ុនថន ៖ ចាន់ ណាវិញ?

អោម ៖ ថាគាត់ឈ្មោះ សេង ហុង ប៉ុនត្រកូលគេហៅតាចាន់ៗ ៗ

ប៊ុនថន ៖ ចុះ ចាន់ ចក្រី ?

អោម ៖ ផ្សេងៗ

ប៊ុនថន ៖ គាត់ធ្វើអី?

អោម ៖ ចាន់ ចក្រី មេទ័ព ឈប់អីត្រឹមហ្នឹងសិនៗ វារៀបរាប់វែងឆ្ងាយណាស់បើរៀបរាប់អាហ្នឹងៗ គាត់ទាក់ទិនរឿងច្រើនណាស់វែងឆ្ងាយណាស់ តាំងពីប្រវត្តិតស៊ូ មុនសម័យខ្មែរក្រហម សម័យបដិវត្តន៍ៗ

ប៊ុនថន ៖ គាត់ទាក់ទងរឿងអីខ្លះ?

អោម ៖ មែនទែន គាត់ឈ្មោះអាចារ្យ នៅៗ ចាន់ ចក្រី ឈ្មោះអាចារ្យ នៅៗ អាចារ្យ នៅ ខាងខ្សែខ្មែរក្រហម សម័យខ្មែរអី ខៀវ សំផន, ហ៊ូ នឹម, ហ៊ូន យន់ៗ គាត់ចូលខាងហ្នឹង ចលនាហ្នឹង ហើយគាត់គេចាប់បានៗ ដល់បែកការណ៍ កាលនោះសម័យសង្គមរាស្ត្រនិយម សម័យសម្តេចឪៗ កាលនោះគេមិនស្រាវជ្រាវរកខ្សែខ្មែរក្រហម អ្នកចលនា អ្នកបះបោរៗ ចាប់គាត់បាននៅកំពង់ចាម ដូចជាយកគាត់ទៅដាក់គុក ក៏ទាក់ទិនរឿងហ្នឹងៗ គាត់រួចពីគុកក៏ចូលមកបួស បួសនឹងក្នុងន័យបន្ទំ ដូចថាបួសលាក់ខ្លួនក្នុងន័យបម្រើចលនាហ្នឹងៗ ដល់សភាពការណ៍ថ្ងៃ១៨ មិនា ឆ្នាំ១៩៧០ មិនរដ្ឋប្រហារៗ ខាងលោក លន់ នល់ ធ្វើរដ្ឋប្រហារសម្តេចតាយើង គាត់មកសឹកនៅថ្ងៃច័ន្ទ នៅបន្ទាយចក្រី ជាប់ព្រំដែនស្រុកកំពង់ត្របែក ជាប់ព្រំដែនយួនៗ បានដាក់ឈ្មោះ ចាន់ ចក្រី សឹកនៅថ្ងៃច័ន្ទនៅបន្ទាយចក្រី ក្នុងស្រុកកំពង់ត្របែកៗ បានលែងឈ្មោះអាចារ្យ នៅ ដាក់ឈ្មោះ ចាន់

ចក្រី សឹកថ្ងៃច័ន្ទ ហើយបន្ទាយចក្រី បានឈ្មោះគាត់ ចាន់ ចក្រី ។ សភាពការណ៍យើងបដិវត្តន៍មិនឈ្នះនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ក៏ចាត់តាំងគាត់ជាសេនាធិការ អគ្គសេនាធិការ ដល់មកចូលប្រជុំនៅសាលសន្និសីទយើងនៅភ្នំពេញ ។ មកដល់គេឃើញមុខ អាចារ្យ នៅ ឈ្មោះ ចាន់ ចក្រី អញអាហ្នឹងក្បត់បានគេចាប់គាត់ទៅ សម្លាប់ចោល ។ គេថា ខ្មែរ សេ អ៊ី អា អីចេះអីចុះ អើកាលនោះអឹមិនបានដឹងមិនបានអីទេ ប៉ុនធាតុពិតវាចឹង អើអាហ្នឹងខ្មែរសេអ៊ីអា ។ អាចារ្យ នៅ ហៅ ចាន់ ចក្រី យកគាត់ទៅបាត់ទៅ អើមិនដឹងជាទៅណា បើបាត់ទៅហើយ ។

ប៊ុនថន : កាលនោះឆ្នាំប៉ុន្មានប្រជុំ?

អោម : ៧៧ ។

ប៊ុនថន : មុន សោ ភឹម ឬក្រោយ សោ ភឹម?

អោម : មុន ស្លាប់មុន សោ ភឹម ។

ប៊ុនថន : កាលនោះគាត់ជាអគ្គសេនាធិការ?

អោម : ជាអគ្គសេនាធិការកងទ័ព អើកាលនោះមិនទាន់មានឈ្មោះ ។ កាលនោះមិនមែនកងទ័ពជាតិ ឬក៏មិនមែនខេមរភូមិន្ទអីទេ ។ និយាយរួម គឺជាអគ្គសេនាធិការនៃកងទ័ពខ្មែរក្រហម ។

ប៊ុនថន : នៅជាមួយតា សុន សេន?

អោម : ហ្នឹងហើយ នៅជាមួយ សុន សេន ។

ប៊ុនថន : គាត់ហើយនឹងតា សុន សេន ពីណាធំជាង?

អោម : ទេ សុន សេន ធំជាង ។ គាត់ខាងកងទ័ព ។

ប៊ុនថន : អ៊ឹដឹងច្រើន?

អោម : ដឹងច្រើន ។ មែនទែន រឿងរ៉ាវធ្វើទាំងអស់គ្នាកាលនោះ មិនដឹងថាស្នេហាជាតិ មិនស្នេហាជាតិម៉េចទេ ។ រឿងថ្ងៃរដ្ឋប្រហារ ១៨ មិនា អឹនៅភ្នំពេញ ។ កាលរដ្ឋប្រហារ ១៨ មិនា ឆ្នាំ១៩៧០ ។ សភាពការណ៍ដុតទូតយួន អាលេកុបទ័រ លន់ នល់ បញ្ហាលើភ្នំពេញទាំងអស់ ។ វាយដុតណោះណោះ ដុតទូតយួន អឹនៅភ្នំពេញ ។

ប៊ុនថន : កាលនោះអឹធ្វើអ្វី?

អោម : កម្មករទាក់ស៊ីក្លូ ប៉ុនមែនទែនជាខ្មែរខ្មែរក្រហម ចង់និយាយឲ្យឆាយស្តាប់ ។

ប៊ុនថន : កម្លាំងសត្វ?

អោម ៈ តស៊ូ ខ្មែរក្រហម ។ ទាល់តែចប់ មើលឡានដឹកនិស្សិតបាតុកម្មពីស្វាយរៀង ដល់ថ្នាក់គេបិទសាឡាងអ្នកលឿងអីទាំងអស់ ។

ប៊ុនថន ៈ ម៉េចបានបិទសាឡាងអ្នកលឿង?

អោម ៈ បិទលែងឲ្យឡានអីឆ្លង អាទៅពីហ្នឹងក៏បិទ អាមកពីហ្នុងក៏បិទ ។ អើកាលនោះនៅអំណាច លន់ នល់ ។ ពួកដឹកនាំនៅ សេនាប្រមុខ លន់ នល់ ហើយសម្ដេចតាយើងជិះយន្តហោះទៅចិន ទៅសូវៀត ។ ប៉ុនថ្ងៃ១៨ អ៊ំនៅចាំរឿងសម្ដេចតាយើងខ្លះដែរ ។ ថ្ងៃ១៨ លន់ នល់ ធ្វើរដ្ឋប្រហារ សម្ដេចតាយើងចេញពីចិនទៅ សុំប្រាប់ចិនថា ខ្ញុំទៅលេងនៅសូវៀតបានពីរបីថ្ងៃ ចិនគេឲ្យយន្តហោះជូនទៅសូវៀត ។ ថ្ងៃ១៨ ម៉ោងប៉ុន្មានទេ តាមមើលឡើងចេញហើយ ប្រាប់សូវៀតថា ខ្ញុំសូមទៅចិនវិញហើយ ចេញពីសូវៀត ។ សូវៀត គេរៀបចំយន្តហោះជូនសម្ដេចតា រៀបចំយន្តហោះ បាយទឹកឲ្យពីព្រឹក ក៏ឡើងយន្តហោះដល់កណ្ដាលផ្លូវ ។ មិនទាន់ដល់ចិន ក៏ទូរស័ព្ទ លន់ នល់ ប្រកាសរដ្ឋប្រហារថ្ងៃ១៨ ដូចជាថ្ងៃត្រង់ សម្ដេចតាយើងស្ទើរនឹងគាំងបេះដូងលើយន្តហោះ រកនឹកមិនឃើញ ។ បើនិយាយភាសាសាមញ្ញ អញអាល័យដើរមកនេះ អ្អែងធ្វើរដ្ឋប្រហារ នឹកស្មានមិនដល់ ។ ប្រហែលម៉ោង៣បានគេអង្វរ រសៀលដល់ចិន ចុះចិនយំស្រក់ទឹកភ្នែកចេញពីយន្តហោះ ។ យើមិនគួរ លន់ នល់ ធ្វើបែបនេះសោះ យប់ថ្ងៃទី១៨ មីនា ១៩៧០ មកសុំវិទ្យុចិននិយាយ ។ អ៊ំនិយាយសម្រាប់យល់ ខ្ញុំសូមខ្ចីវិទ្យុអ្នកឯងនិយាយទៅភ្នំពេញបន្តិចចិនគេឲ្យ មកនិយាយកូនចៅអើយខ្ញុំនៅប៉េកាំង ឥឡូវសូមលោក លន់ នល់ កុំធ្វើចឹង ខ្ញុំទៅវិញហើយចាំដោះស្រាយគ្នា និយាយប្រាប់ លន់ នល់ ។ កាលនោះអ៊ំ ខៀវ សំផន សម្ដេច គេវាយសម្ដេចហើយ បែរជាអង្វរគេ សម្ដេចទៅគេកាត់ក៏ឥឡូវហើយ ។ បានចែងសេចក្ដី៥ខនេះ អើសម្ដេចវាយវាវិញទៅ ហីមកអង្វរគេម៉េច បើគេព្រនង់ដំបងសំពងសម្ដេចប៉ុណ្ណឹងហើយ អង្វរគេម៉េច ដាក់ដំបងមួយវាយគេវិញទៅ បានបង្កើតសេចក្ដី៥ខ បង្កើតរណសិរ្សរួបរួមជាតិ ។ ឪជាសម្ដេច ជាប្រធានរណសិរ្សរួបរួមជាតិ កូនចៅចូលព្រៃម៉ាគី បានខ្មែរក្រហមអូសបាន ។ បានកម្លាំងទាំងអស់ព្រឹបខាងនោះ លន់ នល់ មានស្អី មានទាហានតែប៉ុន្មានកងពល នៅភ្នំពេញ និងតាមស្រុកខេត្ត ។ បានធ្វើប្រធានរណសិរ្សរួបរួមជាតិ កូនចៅអើយចូលព្រៃម៉ាគី ។ ប៉ុណ្ណឹង ឥឡូវអ៊ំមិនបាច់និយាយអីទៀតទេ ហីអ៊ំក៏ចូលព្រៃម៉ាគីដែរ ។

ប៊ុនថន ៈ កាលនោះអ៊ំរត់ទៅខាងណា?

អោម : ទៅទល់ដែនយួនដែរ ប៉ុនយួនខាងណោះ ។ ទៅហាត់រៀន កាំភ្លើងចេញមកព្រាតព្រោង មកវាយ លន់ នល់ វិញ ។

ប៊ុនថន : កាលនោះអ៊ំអត់នៅជាមួយខ្មែរទេ?

អោម : ទេនៅជាមួយខ្មែរយើង ប៉ុនយួនដឹកនាំ ខាងយៀកកុង ។

ប៊ុនថន : ខាងខ្មែរអត់មានដឹកនាំទេ?

អោម : នៅ បានមកបង្កើតមេឃុំ បង្កើតចៅហ្វាយស្រុកបន្តបន្ទាប់ ខាងខ្មែរក្រហម ខាងបដិវត្តន៍ ។

ប៊ុនថន : ពេលណាបានវៀតកុងដកចេញវិញ?

អោម : ៧៥ ពេលឈ្នះហើយបានយួនដឹកទ័ពវាចេញអស់ ដេញចេញ ។ បាន១៧ មេសា យួន ថ្ងៃ៣០ មេសា បានវាយព្រៃនគរបែកអស់បានចូលហាណូយ ។

ប៊ុនថន : ក្រោយយើង?

អោម : ក្រោយយើង ។

ប៊ុនថន : អ៊ំទៅនៅត្របែក និងមានជ័យមានដែលប៉ះគ្នា វាយគ្នា ឈ្លោះគ្នាទេនៅតាមព្រំដែន?

អោម : អត់ទេ ។ ឆ្នាំ៧៩ អាហ្នឹងចូលមក រថក្រោះកងទ័ពវៀតណាមព្រឹង១ចូលមក រត់ចង់និយាយកងទ័ពខ្មែរក្រហមពួកបដិវត្តន៍រត់ឯងតែម្តង ចេះតែរត់បណ្តោះ១ អានោះចេះតែចូលមក ។

ប៊ុនថន : ពីមុនមានវាយគ្នា?

អោម : វាយតាមព្រំដែន ។ ម៉្ដងរយើងខាងសំរោង ខាងរមាស់ហែក ខាងចន្ទ្រា វាយជាមួយពួកខ្មែរក្រហម ជាមួយកងទ័ពវៀតណាម ។ វាយគ្នាបណ្តើរ១ ។

ប៊ុនថន : វាយបណ្តោយខេត្តតែនិញ?

អោម : ពួកនឹងជ្រុលចូលបឹកងពល ។ កាលនោះចង់និយាយខាងកម្លាំងខ្មែរក្រហម ខាងកងពលវាយចូលដល់តៃនិញ បឹកងពល ។

ប៊ុនថន : កងពលអីខ្លះ?

អោម : កាលនោះដូចជា៨០៥ ដៃឆើតហើយខ្លាំងជាងគេ វាយចូលតាយនិញ ។

ប៊ុនថន : ពីណាអ្នកដឹកនាំ?

អោម : អ៊ំភ្លេចឈ្មោះហើយ អាហ្នឹងក៏ខ្លាំងដែរ ។ ចង់និយាយមេកងពល៨០៥ ។ បឹកងពលទៀតចូលវាយយួនដល់តាយនិញ កាលនោះចង់វាយយកខេត្តតាយនិញទាំងមូល ។

ប៊ុនថន : ពីរកងពលទៀត កងពលលេខប៉ុន្មានខ្លះ?

អោម ៖ ខ្ញុំភ្លេចអស់ហើយ ។ អាហ្នឹងសរុបមកវិញ ដល់ចុង៧៨ ខាងយើងសព្វថ្ងៃ ខាងសម្តេច តេជោនាំកម្លាំងយើងទៅចូលខាងនោះ កម្លាំងយើងនេះក៏ចូលមកវិញហើយ ។ អឺរត់ហ្នឹង ឯង រត់ពីស្រុកមានជ័យថ្មី រត់ចេញមកហួសនៅជិតស្រុកថៃ ។

ប៊ុនថន ៖ ៧៩ រត់មកដល់នេះ?

អោម ៖ ដល់នេះ ។

ប៊ុនថន ៖ រត់តៗមក?

អោម ៖ ហួសហើយទៅដល់ស្រះកែវ ចេញពីស្រះកែវ បានមកនៅចំការគ ភ្នំឆ័ត្រ ។

ប៊ុនថន ៖ ចុះពេលសម្តេច ហេង សំរិន សម្តេច ជា ស៊ីម ទៅវៀតណាម អឹមានដឹងទេ?

អោម ៖ ថាដឹង ខ្ញុំនិយាយថាចង់ទៅជាមួយគ្នា ប៉ុនយួនសត្រូវសួរពូជ អើយើងនិយាយពីដូនតា យើងតែងតែនិយាយ ។ កុំអីទៅជាមួយគ្នាហើយ មិនបានមករស់នៅទីនេះទេ ។

ប៊ុនថន ៖ អឹដឹងមុនគាត់រត់ទៅ ក៏ក្រោយមក?

អោម ៖ ដឹងមុនសភាពការណ៍ ផែនការណ៍ដឹង ស្មើឲ្យដកវិទ្យុទាំងអស់លែងឲ្យប្រជាជនស្តាប់វិទ្យុ ។ ប៉ុននៅមានវិទ្យុមួយបើកស្តាប់តែម្នាក់ឯងទេ មិនឲ្យកូនចៅដឹងទេ ។ ពាក្យកូនចៅ មិនមែន កូនគ្រេនទេ អ្នកដែលនៅមន្ទីរ នៅនឹងស្រុក ។ ដកវិទ្យុអស់ ។ ខ្ញុំស្តាប់ផ្សាយព័ត៌មានចេះ ចុះ អើកាលនោះវាយប្រហារ ប៉ុល ពត វាយប្រហារអីនោះ អើនៅវិទ្យុមិនអីចឹង ។ ខាង នោះនិយាយពីរឿងពុករលួយ កាប់សម្លាប់ គេងប្រវ័ញ្ច ។ អឹបានស្តាប់តែម្នាក់ឯងទេ ប៉ុនអាអស់នោះដកអស់ ប៉ុនអត់មាននរណាដឹងព័ត៌មានទេ ។ ប៉ុននៅតែគិតអីចឹង បើអញ ទៅតែម្នាក់ឯង ប៉ុនបើយើងដឹកនាំគេក៏មិនទៅជាមួយយើងដែរ ប៉ុន្តែវានៅនឹកឃើញយួន សត្រូវសួរពូជ ។ ដឹងលោកទាំងអស់ ព្រះអង្គម្ចាស់ទាំងបីព្រះអង្គនាំកងទ័ព លោកតា ហេង សំរិន មិនប្រធានកងពលលេខ៤ គាត់នាំកងពលទៅហើយ ។

ប៊ុនថន ៖ ពេលនាំទ័ពហើយអឹទើបនឹងដឹង ក៏មុននឹងមានគ្រោងការណ៍អឹដឹង?

អោម ៖ ដឹងគម្រោងចូលហើយ ប៉ុនកាលនោះ សោ ភឹម ស្លាប់ហើយ ។ ប្រធានភូមិភាគគេ សម្លាប់ ចាប់គាត់បានហើយ គេសម្លាប់ម៉េចគេមិនដឹងទេ ។ ប៉ុនដឹងលោកតា ហេង សំរិន នាំទ័ពចូលបណ្តើរៗ ប៉ុននៅតែគិតយួនសត្រូវសួរពូជពីដូនពីរតាមក ។ អញទៅដែរប្តុយ៉ាង ម៉េច មិនទៅទេ ហ្នឹងអឹសម្រេចចិត្តខ្លួនឯង ដឹងគ្រោងការណ៍ទាំងអស់ ។

ប៊ុនថន ៖ ចោះក្រៅពីគាត់មានអ្នកផ្សេងរត់ទៅទេ ដូចថាលេខាតំបន់ៗរត់ទៅទេ?

អោម ៖ អត់ទេ ។

ប៊ុនថន : ទៅតែគាត់បីនាក់?

អោម : ហ្នឹងហើយ ខាងនោះទៅតែប៉ុណ្ណឹង។ អ្ហ៊ូ មានផ្សេងទៀតទៅ មើលតំបន់ខាងនោះមាន ២១, ២២ ។

ប៊ុនថន : ២២ ពីណា?

អោម : អ្ហ៊ូ២២ ស្អីទេ ប៉ុន២១ តា ជា ស៊ីម ។ តាមមើលគាត់ទៅដែរ ព្រោះនៅជាប់គ្នានោះ។ ដោយឡែកតែអ៊ឹនៅខាងតំបន់២៣, ២៤ ខាងព្រៃវែង ខាងស្វាយរៀង ។

ប៊ុនថន : ពេលគាត់រត់ចេញទៅ មានប្រជុំទេ?

អោម : អត់មាន ពេលកាលនោះ បានតែប្រជុំដាច់ក ។

ប៊ុនថន : ខាងលើកោះប្រជុំ?

អោម : ចង់និយាយ...។

ប៊ុនថន : គាត់រត់ទៅមានកោះប្រជុំប្រធានៗ ?

អោម : មាន ខាងខ្មែរក្រហមមាន ដូចអ៊ឹសភាពការណ៍ដល់កហើយ ទឹកដល់កហើយ ខ្មែរក្រហម កាលនោះមានគោលការណ៍ដែរ ។ ដល់ដឹងរឿងសភាពការណ៍ជិតដាច់ករហើយ ប្រជុំរឿង ទីមួយ កាលនោះពេលជម្លៀសពីភ្នំពេញទៅ គេមិនរៀបរយមានប្រជាជនពេញសិទ្ធិ មាន អ្នកផ្ញើ មានអ្នកផ្ញើអីតាមសហករណ៍ ។ ហីឲ្យវាបន្ធូរសភាពការណ៍ ចាំខ្ញុំប្រាប់ ឲ្យឥឡូវឲ្យ រកដោះស្រាយសភាពការណ៍គ្រប់យ៉ាងទាំងអស់ ។ អ៊ឹនឹកថា ឥឡូវដល់កហើយបានធ្វើ អីចឹង បើពីមុនដូច្នេះមិនចាញ់គេទេ ដូចថា ដោះស្រាយហូបចុកគ្រប់គ្រាន់ កុំកាប់សម្លាប់ កុំរកអាណាប្រពន្ធទាហាន ប្រពន្ធសក្តិមួយ សក្តិពីរ ។ កាលនោះធ្វើតាមនោះឯង ធ្វើដោះ ស្រាយ ជិនាន់អាជិតដាច់៧៩ហើយហ្នឹង ។ ចុង៧៨ហើយបានថា លែងគិតពីសក្តិមួយ សក្តិពីរ ឲ្យតែខ្មែរ ឲ្យតែប្រជាជន រួបរួមគ្នា ផ្សះផ្សាគ្នាទៅ ។ ហ្នឹងចុងកន្ទុយហើយ ប៉ុន សភាពកការណ៍នឹងដល់ហើយ អ៊ឹដឹងដែរ ។ ខាងនោះវាយតាមព្រំដែនបណ្តើរៗហើយ កិល ចូលបណ្តើរៗហើយ ។ ប៉ុនដូចអ៊ឹនិយាយអីចឹង អញទៅដែរឥឡូវ នេះគេនិយាយលេងក្នុង ចិត្ត អ្ហ៊ូអាសត្រូវស្នូរពូជ អញមិនទៅជាមួយអ្ហែងទេ ។ វានៅតែប៉ុណ្ណេះ ។

ប៊ុនថន : គេវាយជាមួយគ្នា ចុះប្រជាជន?

អោម : គេជម្លៀសមកអស់ហើយ ដែនការជម្លៀសអស់ហើយ តាំងពីសំរោង រមាសហែក ចន្ទ្រា ស្រុកក្រសាំង ប្រសូត្រ ។

ប៊ុនថន : ជម្លៀសទៅណា?

អោម ៖ ជម្លៀសមកនេះឯង មកលិចរហូត ។ អឹមិនដឹងគេដោះស្រាយយ៉ាងម៉េច អឹមិនយល់ដល់ ។

ប៊ុនថន ៖ នៅតែកង់ទ័ព?

អោម ៖ នៅតែកង់ទ័ព ប្រជាជនជម្លៀសអស់ហើយ ។ អញ្ចឹងមែនទែនអឹយល់រឿងច្រើនណាស់ ព្រោះអ្នកធ្វើរហូតទល់មកឥឡូវ ។ ហីចឹងរឿងកាលនោះ ចុង៧៨នេះ ប្រជាជនព្រំដែន តាំងពីស្រុករមាសហែក ស្រុកប្រសូត្រ ស្រុកចន្ទ្រា ស្រុកសំរោង ជម្លៀសមកអស់រលីង គ្មាននៅទេ នៅតែកង់ទ័ព ។

ប៊ុនថន ៖ មានប្រជាជនរត់ឆ្លងដែនចូលទៅខាងយួនទៀតទេ?

អោម ៖ មាន ប៊ុនភាគតិច ខាងពាមជរ ខាងអីរត់ទៅវៀតណាម ហើយនៅខាងត្បូងឆាយ មាន បន្ទាយចក្រី ពាមពារ កលរការ បន្ទាយដែកវាជិត ។

ប៊ុនថន ៖ ចោះនៅខាងស្វាយរៀង មានរត់ចូលទេ?

អោម ៖ មាន ប៊ុនភាគតិចណាស់ ។

ប៊ុនថន ៖ រត់ចូលទៅនៅណា?

អោម ៖ រត់ទៅសុំជ្រកកោននៅប្រទេសវៀតណាម ព្រោះចប់សព្វគ្រប់បានគ្នាចេញមកវិញ ។

ប៊ុនថន ៖ ចោះមានប្រជាជនវៀតណាមនៅខ្មែរទេ?

អោម ៖ កាលនោះមិនមានទេ គ្រាន់អ្នករកចេញចូលព្រឹកល្ងាចជាមួយគ្នា ស្និទ្ធស្នាលដូចមិត្តភក្តិ បង បងប្អូនមាន ប៊ុនកាលនោះមិនទាន់មានមកទេ ។ ខាងវៀតណាមមិនទាន់មានមកនៅទឹកដី យើងទេ ។

ប៊ុនថន ៖ មុននេះអឹថាកងពល៨០២វាយចូលវៀតណាម ។ តើវាយចូលបានយូរទេ?

អោម ៖ នៅមិនដល់បានមួយខែទេ ។ ខាងអា ផល អានោះមេខ្លាំងខាងខ្មែរក្រហម ប៊ុនពួកហ្នឹងនៅ ជ្រុល ។ ដល់កងទ័ពវៀតណាមចូលលើកទ័ព កាំភ្លើងធំវាយបែក ចូលដល់ភ្នំពេញហើយ បានអាពួកនោះរត់មកតាមព្រៃវិញ ។

ប៊ុនថន ៖ ដល់ពេលខាងវៀតណាមវាយចូលដល់ភ្នំពេញហើយ បានរត់ចេញមក?

អោម ៖ ហ្នឹងហើយ វាថាខកខ្លួននៅបីកងពល បានវារត់ចេញមកតាមក្រោយ ចេញមកតាមតាយ និញ ។ មករហេចរហាច ចោលកាំភ្លើង ចោលខោ ចោលអាវ រត់តែខ្លួនមករៀងៗខ្លួន ។

ប៊ុនថន ៖ កាលជំនាន់នោះអឹមានដែលជួបតាៗ ឡើងប្រជុំជាមួយតាៗនៅភ្នំពេញទេ?

អោម ៖ អឹដូចថា ដាច់សេវាតាំងពីពេលនោះមក ។

ប៊ុនថន ៖ កាលបីឆ្នាំ?

អោម ៖ អត់ដែលជួបទេ ។

ប៊ុនថន ៖ អត់ដែលឡើងប្រជុំនៅភ្នំពេញ?

អោម ៖ អត់ទេ ។

ប៊ុនថន ៖ កាលនោះមានប៉ុន្មានតំបន់ភូមិភាគបូព៌ា?

អោម ៖ ២១, ២២, ២៣, ២៤ មានបួនតំបន់ ។ ភូមិភាគបូព៌ា ហៅភូមិភាគ២០៣ អ៊ីចាំបាន តែប៉ុណ្ណឹង ។

ប៊ុនថន ៖ ចោះបន្ទាប់ពី សោ ភឹម ពីណាអនុលេខាបូព៌ា?

អោម ៖ តាចាន់ ស្លាប់ជំនាន់៧៩ ។ ស្លាប់បាត់ឈ្មោះទាល់តែឥឡូវ ។

ប៊ុនថន ៖ ចុះតា ធុច អ៊ីស្គាល់ទេ?

អោម ៖ ស្គាល់ ។

ប៊ុនថន ៖ គាត់នៅខាងណា?

អោម ៖ គាត់កាលនោះនៅ២៤ ។

ប៊ុនថន ៖ តំបន់?

អោម ៖ តំបន់២៤ ។

ប៊ុនថន ៖ នៅក្នុងភូមិបូព៌ា?

អោម ៖ ក្នុងបូព៌ាដែរ ។

ប៊ុនថន ៖ គាត់ប្រធាន?

អោម ៖ អ្ហ៊ុ គាត់ប្រធានសេដ្ឋកិច្ច២៤ ។

ប៊ុនថន ៖ ពេលក្រោយមកគាត់ឡើងជាលេខា?

អោម ៖ អត់ទេ គាត់បាត់ខ្លួនតាំងពីមុនសភាពការណ៍ ។ ចង់និយាយថា គណតំបន់២៤ តាឈូក តាធុច តាជ័យ ។ គាត់បាត់ ដល់បាត់ឈ្មោះគាត់ បានចេញពីភាគមក ។ ចង់និយាយ គេយកគណៈភូមិភាគមកគ្រប់គ្រងតំបន់២៤-២៣ គេហៅតំបន់ក្លោះ ហៅតំបន់ក្លោះកាល នោះ ។ អាហ្នឹងហើយ ដែលគេចាត់តាំងអ៊ីឲ្យដើរមើល មើលនោះមិនមើលអីទេ មើល តើប្រជាជនគ្រប់តំបន់ ទីតំបន់នោះហូបយ៉ាងម៉េច ស្លៀកពាក់យ៉ាងម៉េច សុខភាពយ៉ាង ម៉េច ត្រឹម៧៨ហ្នឹងឯង ។

ប៊ុនថន ៖ ដើរគ្រប់តំបន់?

អោម ៖ តែពីរតំបន់ទេ ស្វាយរៀង និងព្រៃវែង។ អាហ្នឹងដែលអ៊ំនិយាយអំបិញមិញ អ៊ំដឹងសភាពការណ៍ ដល់អ៊ំចុះគ្រប់បានដឹងរឿងហ្នឹង។ ដឹងរឿងសភាពការណ៍ ដូចអ៊ំនិយាយអំបិញមិញអញទៅដែរឥឡូវ ប៉ុនអាយួនសត្រូវសួរពូជ បើអញចូលយួនទៀតដូចជាមិនកើតទេ បើអញចូលយួនទៀត។ កុំអីទៅជុំជាមួយគាទាំងបី។

ប៊ុនថន ៖ កាលនោះអ៊ំដើរមើលសភាពការហើយបានរាយការណ៍ទៅលើ?

អោម ៖ អត់ទេ អត់ធ្វើរបាយការណ៍ទៅណាទេ គ្រាន់តែដឹងចិត្តដឹងខ្លួន ហើយនៅឲ្យស្ងៀម។ ប៉ុនជម្លៀសដឹងដែនការ កាលនោះគេហៅ៨៧០ ចេញពីលេខាទៅ បញ្ជាឲ្យជម្លៀសប្រជាជនពីដែនឲ្យអស់ ហើយចេះតែដឹកបញ្ជូនៗមក មិនដឹងជាទៅណាទៅណី។

ប៊ុនថន ៖ បញ្ជាពី៨៧០?

អោម ៖ ៨៧០ ពីភ្នំពេញ។

ប៊ុនថន ៖ បញ្ជាទៅផ្ទាល់ ឬចេញពីភូមិភាគហើយ បានទៅអ៊ំ?

អោម ៖ អត់ទេ។ ទៅខាងស្រុក ខាងតំបន់គេតែម្តង ទៅលេខាតំបន់។ ប៉ុនមែនទែន តំបន់២៣ គា សិន គេចាប់។

ប៊ុនថន ៖ ឈ្មោះអី សិន?

អោម ៖ នៅលើអ៊ំជាអ្នកដើរ វាមិនមែនជាគណៈតំបន់ទេ ប៉ុន្តែអំណាច ចង់និយាយបទបញ្ជាគឺមានតែអ៊ំ ជម្លៀសប្រជាជនតាមព្រំដែន ហើយសភាពការណ៍ចេះផ្ទុះបណ្តើរៗហើយ។ ហើយចេះតែឲ្យចេញមកបណ្តើរៗមក បញ្ជូនមកតែខាងលិច មកភ្នំពេញមក តែមិនដឹងទៅណាមកណាអ៊ំមិនបានដឹងទេ។

ប៊ុនថន ៖ គា សិន ឈ្មោះអី សិន?

អោម ៖ គណៈតំបន់២៣!

ប៊ុនថន ៖ បាទ?

អោម ៖ មិនបានស្គាល់ត្រកូលគាត់ ឈ្មោះ គាសួរ។

ប៊ុនថន ៖ ចោះគណៈភូមិភាគ?

អោម ៖ ឈ្មោះ គាចាន់ អំបិញមិញ មួយឈ្មោះ គាភួង។ ប៉ុន គាភួង បាត់ឈ្មោះមិនឃើញឃើញតែ គាចាន់ មួយមក។ មកចេញជាតំណាងភូមិភាគ គាចាន់ ប៉ុនអ៊ំមិនយល់ដល់រឿងអី ដល់ថ្នាក់យកមកកាប់សម្លាប់ មកវាយចោលអីទេ ព្រោះអ៊ំនិស្ស័យរឿងស្នេហា

ជាតិ ស្រឡាញ់ជាតិ ។ ហើយមិនដឹងគេយកមកវាយបងប្អូនយើង ប្រជាជនយើង វាយចោល សម្លាប់ចោលយ៉ាងម៉េចៗមិនដល់រឿងហ្នឹង ។

ប៊ុនថន : អ៊ំនៅខាងលើអត់ដឹង?

អោម : អត់ដឹង ។ ចេះតែធ្វើតាមបទបញ្ជា៨៧០ ។

ប៊ុនថន : គេបញ្ជាទៅផ្ទាល់ទៅតំបន់ ឬតំណាងភាគសិន?

អោម : ត្រូវមកភាគ ភាគគេឲ្យអ៊ំតែម្តង ចង់និយាយចេញពីភាគ ព្រោះគណៈតំបន់ចាប់អស់រលីងហើយ ។ ភាគធ្វើអីចឹង យើងចេញតាមស្រុក ឥឡូវជម្លៀសបងប្អូន សភាពការណ៍ចោះវាយតាមព្រំដែន គេធ្វើតាមយើង ។

ប៊ុនថន : ស្លាប់ច្រើនទេ ទាហាន ឬប្រជាជនស៊ីវិល?

អោម : អត់ទេ សុទ្ធស៊ីវិល ប្រជាជនយើងស្លាប់តាមសហករណ៍ ។ ចេះតែបញ្ជូនៗជម្លៀសៗ មិនដឹងជាធ្វើការធ្វើម៉េចៗ អត់មានយល់ការណ៍ទេ ។ មើលទៅដំបូង អ៊ំទៅកំពង់រោទិ៍ អានោះចាប់គណៈស្រុកកំពង់រោទិ៍ហើយ ទៅដល់សួរអាអ្នកនៅក្នុងគុក៤០០នាក់ជាង ដែលយកទៅដាក់កន្លែងឃុំឃាំង ។ ខ្ញុំទៅដល់ក៏លែងទាំងអស់ អាប្រធានគុក មើលឥឡូវអ្នកទោសប៉ុន្មាន ថា៤០០ជាង ឲ្យលែងមកទាំងអស់ ។ ហឺមើលទោសអីខ្លះ ខ្លះភ្ជួរបាក់នង្គ័ល ខ្លះខុសសីលធម៌ អើគេរាប់រៀប ។ ឥឡូវលែងទាំងអស់ ទៅសហករណ៍ណា តាមឃុំណាៗ សហករណ៍ណាទៅវិញ ។ និយាយពីលើកដៃថ្វាយបង្គំអ៊ំ អើព្រះម្ចាស់អើយមកជួយខ្ញុំលែងទាំងអស់ ។ ទោសប៉ុណ្ណឹងៗ យកមកដាក់គុកធ្វើអី នាំគ្នាទៅរកស៊ី ធ្វើការណ៍នៅសហករណ៍ណាទៅវិញ ។ លើកដៃថ្វាយព្រះអើយមកជួយខ្ញុំ ចោះអរណាស់ គ្នាអ្នកជាប់គុកពីរបីខែហើយនោះ ។ ខ្ញុំដោះលែងទាំងអស់ហ្នឹងអ្ហែងនៅស្រុកកំពង់រោទ៍ ។

ប៊ុនថន : កន្លែងនោះគេហៅភូមិឃុំអី មាននៅចាំទេ?

អោម : ខាងលិចខេត្តបន្ទិច គេហៅភូមិកន្ទុយវៃ ។

ប៊ុនថន : កន្លែងនោះគេហៅមេភ្លើង ឬគោមបី ។ នៅម្តុំហ្នឹង?

អោម : មិនមែនទេ ខាងលិចខេត្តស្វាយរៀងប្រហែលបីគីឡូ ។ ត្រង់នោះមានអូរមួយ មានស្ពានមួយ ។

ប៊ុនថន : ស្ពានកន្ទុយវៃ?

អោម : ស្ពានកន្ទុយវៃ ហើយមន្ទីរស្រុកកំពង់រោទិ៍ នៅហ្នឹងកន្ទុយវៃ ។

ប៊ុនថន : នៅកន្លែងមួយទៀតនៅឃុំស្វាយតឿ អ៊ំមាននៅចាំទេ?

អោម : ស្វាយទាបមាន ស្វាយតឿមិនមានទេ ។

ប៊ុនថន : ឃុំស្វាយតឿ ស្រុកកំពង់រោទិ៍? ភូមិតាណរ៍

អោម : មើលស្វាយតឿ...។

ប៊ុនថន : ជាប់ព្រែក ជាប់ប្រាសាក់?

អោម : កាលហ្នឹង ចេញពីស្វាយរៀងមក គេហៅប្រសូត្រ ផ្លូវបែកមកត្បូង ។

ប៊ុនថន : អត់ដល់ប្រសូត្រទេ ចេញពីទីរួមខេត្តស្ពាន?

អោម : ត្រើយតាហោរ ។

ប៊ុនថន : មកត្រង់មក បត់ខាងស្តាំដៃ នៅជិតវត្ត ទល់មុខវត្ត?

អោម : អឹមិនបានសួរស្គាល់ដែរទេ?

ប៊ុនថន : គេហៅឃុំស្វាយតឿ?

អោម : អើអឺយល់ហើយ អានោះផ្លូវបត់ស្តាំមកត្បូង ។ ហើយត្រង់ហ្នឹងយ៉ាងម៉េច ។

ប៊ុនថន : កន្លែងនោះមានកន្លែងឃុំមួយ អឺដែលទៅដល់ហ្នឹងទេ?

អោម : អឺមិនដែលទៅដល់ទេ ស្វាយតឿដឹង ។

ប៊ុនថន : អឺដើរសព្វកន្លែងទាំងអស់?

អោម : សព្វកន្លែង តែមិនបានល្អិតល្អន់ទាំងអស់ទេ នៅឆកល្វែង ។

ប៊ុនថន : កាលនោះស្រុកកំពង់រោទិ៍មកដល់ទីរួមខេត្ត?

អោម : មកទល់នឹងត្រើយតាហោរ បេកខាងត្បូងថ្នល់ ។

ប៊ុនថន : ម៉េចមន្ទីរនៅខាងកន្ទុយវៃ?

អោម : អ៊ូ មកនៅក្រោយទេ មកនៅក្បែររោងម៉ាស៊ីនស្រូវកន្ទុយវៃ មន្ទីរស្រុកកំពង់រោទិ៍ ហើយបើទៅកើត ស្រុកប្រសូត្រ ។ គេរៀបចំស្រុកប្រសូត្រ ។

ប៊ុនថន : កាលនោះមានស្រុកស្វាយរៀង?

អោម : មាន មកលិច ត្រើយលិច ។ ខាងលិចកំពង់រោទិ៍ ខាងលិចខេត្ត ស្រុកស្វាយរៀង ។ ស្រុកស្វាយរៀងហើយ បានស្រុកមានជ័យថ្មី ឥឡូវគេហៅស្រុកស្វាយទាប ។ ឥឡូវគេរៀបរយស្រុកស្វាយជ្រំ កន្លែងវត្តព្រះពូកែ ។

**-ចប់-**